ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១២២

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩

សាលដីកា

លេខ ៣៧ IV

ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជាសាធារណៈ ពិភាក្សាដេញដោល ស្តាប់សេចក្តីសន្និដ្ឋានភាគីពាក់ព័ន្ធ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.លោក [redacted] ជាចៅក្រម

៣.លោក [redacted] ជាចៅក្រម

៤.លោក [redacted] ជាចៅក្រម

៥.លោកស្រី [redacted] ជាចៅក្រម

## ចៅក្រមរបាយការណ៍

-លោក [redacted]

## ក្រឡាបញ្ជីសវនាការ

-កញ្ញា [redacted]

## តំណាងមហាអយ្យការ

-លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រIIIប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

បុគ្គលប្តឹងសាទុក្ខ ៖ ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស កើតឆ្នាំ១៩៨១ សញ្ជាតិខ្មែរ មុខរបរកសិកម្ម ទីកន្លែងកំណើតនៅភូមិឯន ឃុំឯន ស្រុកសណ្តាន់ ខេត្តកំពង់ធំ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted]។ ទោសពីមុនគ្មាន។

មានលោកមេធាវី [redacted] ចមុល និងលោកស្រី [redacted] សុវណ្ណារិទ្ធិ ជាអ្នកការពារ។



Scanned with CamScanner

ជាប់ចោទពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិវាលព្រីង ឃុំងន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមបទប្បញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង ភេទស្រី អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាន ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ធំ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ២២:១៥ នាទី នៅភូមិវាលព្រីង ឃុំងន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ មានជនមួយក្រុមបានទៅវាយប្រពន្ធនិងកូនជនរងគ្រោះឈ្មោះ [redacted] ហឿន ភេទប្រុស អាយុ ៤៨ ឆ្នាំ ប្លន់យកលុយ ដុតបំផ្លាញទ្រព្យសម្បត្តិ និងបានចាប់វាយធ្វើទារុណកម្ម ជនរងគ្រោះ ចងកអូសតាមផ្លូវយកទៅមាត់ស្ទឹងសែន ឃុំងន រួចអាករសម្លាប់ រួចអូសទម្លាក់ទឹកស្ទឹង។ ក្រោយពេលកើតហេតុសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ហ៊ីន ហៅ [redacted] ហ៊ីន ; [redacted] ហេង , [redacted] មី និងឈ្មោះ [redacted] ហៃ ឯបក្សពួកមួយចំនួនទៀតបានរត់គេចខ្លួន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឃ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលា ដំបូងខេត្តកំពង់ធំដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសឈ្មោះ៖-[redacted] ហេង ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ

[redacted] ហៃ ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ

-[redacted] មី ភេទប្រុស អាយុ ៣១ ឆ្នាំ ជាតិខ្មែរ

-[redacted] ហ៊ី ហៅ [redacted] ហ៊ី ភេទប្រុស អាយុ ៤៧ ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ១៣ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ។

និងផ្តន្ទាទោសលើឈ្មោះ ៖

[redacted] សុខា ភេទប្រុស អាយុ ២៦ ឆ្នាំ ជាតិខ្មែរ

-[redacted] ឡំ ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ

-[redacted] ស៊ី ភេទប្រុស អាយុ ៣៧ ឆ្នាំ ជាតិខ្មែរ

[redacted] ធុន ភេទប្រុស អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ

[redacted] នីម ភេទប្រុស អាយុ ១៩ ឆ្នាំ ជាតិខ្មែរ

[redacted] យ៉ីន ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ



Scanned with CamScanner

[redacted] យ៉េត ភេទប្រុស អាយុ ៣៩ ឆ្នាំ ជាតិខ្មែរ

[redacted] សុក ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ

[redacted] សេន ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ

[redacted] សល់ ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ

[redacted] ដែន ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ

[redacted] អ៊ុយ ភេទប្រុស អាយុ ១៨ ឆ្នាំ ជាតិខ្មែរ

[redacted] គ្រីម ភេទប្រុស អាយុ ១៩ ឆ្នាំ ជាតិខ្មែរ

[redacted] ចេក ភេទប្រុស អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ

[redacted] ហេង ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ

[redacted] វុន ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ

[redacted] យឹម ភេទប្រុស អាយុ ២៣ ឆ្នាំ ជាតិខ្មែរ

[redacted] ខុន ភេទប្រុស អាយុ ១៦ ឆ្នាំ ជាតិខ្មែរ

[redacted] សាង ភេទប្រុស អាយុ ២៨ ឆ្នាំ ជាតិខ្មែរ

[redacted] ឆុម ភេទប្រុស អាយុ ២៩ ឆ្នាំ ជាតិខ្មែរ

[redacted] មី ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ

[redacted] ឡេ ភេទប្រុស អាយុ ៥៣ ឆ្នាំ ជាតិខ្មែរ

[redacted] ជាតិ ភេទប្រុស អាយុ ២៤ ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ១៣ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។

ពីបទឃាតកម្ម ប្រព្រឹត្តនៅភូមិវាលព្រីង ឃុំងន ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសដែលមានបញ្ញត្តិនិងឱ្យផ្តន្ទាទោសតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-ផ្តន្ទាទោសឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ ២៤ ឆ្នាំ ជាតិខ្មែរ

[redacted] កេន ហៅ [redacted] -កេន ភេទប្រុស អាយុ ២៨ ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ១៥ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានពីបទឃាតកម្ម ប្រព្រឹត្តនៅភូមិវាលព្រីង ឃុំងន ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោស តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។



Scanned with CamScanner

២.បង្គាប់ឱ្យជនជាប់ចោទ ដែលមានឈ្មោះដូចខាងលើ រួមគ្នាសងប្រាក់ជំងឺចិត្តចំនួន ៥០.០០០.០០០ (សែសិបលាន) រៀលគត់ ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ។ ការប្តឹងទាមទារលើសពីនេះបដិសេធចោល។

៣.វត្ថុតាងចាប់យកមាន៖ ដំបងឈើចំនួន ១២ , ពូថៅចំនួន ០១ , ដែកសរសៃថ្នាំងអំពៅចំនួន ០១, ដាវចំនួន ០១, កាំបិត[ចិតផ្កា]ត្នោតចំនួន ០១, ខោចំនួន ០១ និងខ្សែទីឡុងចំនួន ០១ ដុំ ត្រូវរឹបអូស និងបំផ្លាញចោល។

៤.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហេង, [redacted] ហៃ, [redacted] ម៉ី, [redacted] ហ៊ីន ហៅ [redacted] ហ៊ីន, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជឿន, [redacted] កេន ហៅ [redacted] កេន, [redacted] សុខា, [redacted] ឡុំ, [redacted] ស៊ុំ, [redacted] អុន, [redacted] នឹម, [redacted] យ៉ឺន, [redacted] យ៉េត, [redacted] សុក, [redacted] សេន, [redacted] សល់, [redacted] ផែន, [redacted] អ៊ីុយ, [redacted] គ្រឹម, [redacted] ចេក, [redacted] ហេង, [redacted] វុន, [redacted] ឃឹម, [redacted] ខុន, [redacted] សាង, [redacted] ផុង, [redacted] មី, [redacted] ជាតិ និង [redacted] ឡេ ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងទាស់លេខ ៣២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ របស់លោកស្រី [redacted] សុវណ្ណារិទ្ធិ ជាមេធាវីតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] សុខា ក្នុងការប្តឹងទាស់ មិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ “ឃ” ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.តម្កល់សាលក្រមលេខ ០៩ “ឃ” ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាត្រឹមត្រូវដដែល ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ។

២.សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខា និងចាត់ទុកចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហុង ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ របស់លោកស្រី [redacted] សុវណ្ណារិទ្ធិ ជាមេធាវីតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] សុខា ក្នុងការប្តឹងឧទ្ធរណ៍មិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។



Scanned with CamScanner

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ប.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.បណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ របស់លោកស្រី [redacted] សុវណ្ណារិទ្ធិ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការពេញទាំងមូល។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

៤.សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

-បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ប.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការ ហើយដែលសាលក្រមនេះក៏បានសម្រេចតាមបណ្តឹងទាស់របស់ជនជាប់ចោទដោយបានតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំលេខ ០៩ (ឃ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានដដែលនោះ គឺមានសំអាងហេតុនិងកស្តុតាងត្រឹមត្រូវតាមច្បាប់ហើយ ព្រោះថា៖

តាមចម្លើយសារភាពរបស់ជនជាប់ចោទ ៤ នាក់ ដែលចាប់ខ្លួនក្រោយពេលកើតហេតុ ស៊ីចង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ព្រមជាមួយចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខា (ម្ចាស់បណ្តឹងសាទុក្ខ) នៅសាលាដំបូង ពេលជំនុំជម្រះលើបណ្តឹងទាស់របស់សាមីខ្លួន ដូចមានក្នុងសំអាងហេតុចំណុចទី ២, ទី ៣, ទី ៤ និងទី ៨ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។



Scanned with CamScanner

ហេតុដូច្នេះ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ប.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] សុខា បានឆ្លើយថា ខ្លួនកើតនៅឆ្នាំ១៩៨១ ហើយប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ម៉ៅ មិនមែនឈ្មោះ [redacted] ម៉ៅ នោះទេ ។

-លោកស្រី [redacted] សុវណ្ណារិទ្ធិ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខា បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនប្ដឹងសាទុក្ខនេះ គឺដោយសារតែមានភាពអយុត្តិធម៌ចំពោះការផ្ដន្ទាទោស។ សាក្សីនៅតុលាការថ្នាក់ក្រោមក៏បានបញ្ជាក់ថា កូនក្ដីរបស់ខ្លួនពុំមានវត្តមានក្នុងពេលកើតហេតុទេ ហើយដើមបណ្ដឹងគ្រាន់តែបញ្ជាក់ថា កូនក្ដីខ្លួនទៅដណ្ដើមលុយពីគាត់តែប៉ុណ្ណោះ។ រីឯកូនរបស់ជនរងគ្រោះក៏បានឆ្លើយដែរថា ពុំមានវត្តមានរបស់កូនក្ដីខ្លួនទេ ដែលវាស៊ីចង្វាក់គ្នាទៅនឹងចម្លើយសាក្សី ចំណែកឯទីតាំងដែលជនរងគ្រោះត្រូវគេសម្លាប់គឺនៅឆ្ងាយពីទីលំនៅរបស់កូនក្ដីខ្លួន កូនក្ដីរបស់ខ្លួនពុំដែលមានទំនាស់ជាមួយនឹងជនរងគ្រោះនោះទេ ប៉ុន្តែកូនក្ដីខ្លួនមានទំនាស់ជាមួយដើមបណ្ដឹងទៅវិញទេ។ ការផ្ដន្ទាទោសទៅលើកូនក្ដីរបស់ខ្លួនចំនួន ១៣ ឆ្នាំ វាមានភាពអយុត្តិធម៌ដល់កូនក្ដីខ្លួនណាស់ ព្រោះវាធ្វើឱ្យបាត់បង់សេរីភាព ដូច្នេះ សូមតុលាការកំពូលមេត្តាពិចារណាទៅលើសាក្សីដែលបានឆ្លើយនៅតុលាការថ្នាក់ក្រោម ។ ខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តាលើកលែងការចោទប្រកាន់ទៅលើកូនក្ដីរបស់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] សុខា បានឆ្លើយបន្ថែមថា ខ្លួនប្ដឹងសាទុក្ខនេះពុំទាន់ហួសរយៈពេលនៃបណ្ដឹងសាទុក្ខនោះទេ ហើយការដែលខ្លួនប្ដឹងនេះ គឺដោយសារតែការផ្ដន្ទាទោសលើខ្លួននោះមានចំនួនច្រើនពេក ខ្លួនពុំបានសម្លាប់មនុស្សនោះទេ។ ខ្លួននៅផ្ទះរបស់ដើមបណ្ដឹងឯណោះទេ។ ឯជនរងគ្រោះនៅឯផ្ទះម្ដាយមីងរបស់គាត់។ ខ្លួនពុំដែលមានទំនាស់អ្វីជាមួយជនរងគ្រោះទេ ហើយខ្លួនក៏ពុំបានដណ្ដើមលុយពីដើមបណ្ដឹងនោះដែរ។ ខ្លួនគ្រាន់តែវាយឱ្យដើមបណ្ដឹងរត់តែប៉ុណ្ណោះ។ ខ្លួនពុំបានដឹងថាជនរងគ្រោះចេះមន្តអាគមអ្វីទេ។ ខ្លួនបានវាយឈ្មោះ មុំ ជាកូនស្រីរបស់ជនរងគ្រោះ និងដើមបណ្ដឹងចំនួនមួយដៃ។ ហើយទីតាំងកើតហេតុ គឺនៅឯផ្ទះដើមបណ្ដឹងចម្ងាយប្រហែល ៣០ ម៉ែត្រ ពីកន្លែងកើតហេតុ ។ មើលពុំឃើញទេ ព្រោះមានដើមឈើបាំង។ ខ្លួនពុំបានចូលរួមប្រព្រឹត្តក្នុងអំពើឃាតកម្មនោះទេ គឺដូចអ្វីដែលមេធាវីរបស់ខ្លួនបានសន្និដ្ឋានរួចហើយ។ ខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តាលើកលែងការចោទប្រកាន់មកលើខ្លួន។

-កាលដែរខ្លួនវាយកូនស្រីនិងដើមបណ្ដឹង គឺដើម្បីឱ្យពួកគេរត់ ព្រោះឃើញអ្នកភូមិដេញតាមចាប់ជនរងគ្រោះ។

-លោកស្រី [redacted] សុវណ្ណារិទ្ធិ បានធ្វើសេចក្ដីសន្និដ្ឋានបន្ថែមថា ការដែលកូនក្ដីខ្លួនឆ្លើយថាខ្លួនដឹងកំហុសហើយ សូមបន្ធូរបន្ថយទោសដល់ខ្លួនផង នោះគឺដោយសារតែខ្លួនជាអ្នកបង្គាប់ឱ្យកូនក្ដីខ្លួននិយាយ តែមិនមែនមានន័យថា ឱ្យទទួលស្គាល់នូវរឿងឃាតកម្មនេះនោះទេ គឺជារឿងហិង្សាទៅវិញទេ។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ឧ.ប ចុះថ្ងៃទី៣១ ខែតុលា ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងខុសនឹងបញ្ញត្តច្បាប់ ដោយហេតុថា បណ្តឹងសាទុក្ខនេះរបស់ជនជាប់ចោទ ធ្វើឡើងផុតរយៈពេលអាចប្តឹងសាទុក្ខដែលច្បាប់កំណត់រយៈពេល ១ (មួយ) ខែ ចំពោះសាលដីកាចំពោះមុខ។ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទបានធ្វើឡើងហួសរយៈពេលច្បាប់កំណត់រហូតដល់ ១ ខែនិង ១០ ថ្ងៃឯណោះ។ ដោយហេតុថា សាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ឧ.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ជាសាលដីកាចំពោះមុខជនជាប់ចោទ ដូច្នេះរយៈពេលដែលឈ្មោះ [redacted] សុខា អាចប្តឹងសាទុក្ខនឹងសាលដីកានេះបាន តែក្នុងថិរវេលាមួយខែគត់ គិតចាប់ពីថ្ងៃប្រកាសសាលដីកា ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ គឺបានត្រឹមតែ តែថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ប៉ុណ្ណោះ ពីព្រោះសាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ឧ.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ នេះរបស់សាលាឧទ្ធរណ៍ភ្នំពេញ ជាសាលដីកាចំពោះមុខ។ ដោយមូលហេតុនេះហើយ តុលាការកំពូលពុំអាចលើកយករឿងក្តីនេះមកជំនុំជម្រះវិនិច្ឆ័យសេចក្តីបាននោះទេ យោងតាមបទប្បញ្ញត្តិមាត្រា ៤២០ កថាខណ្ឌទី ១ ចំណុចទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តអំពីរយៈពេលដើម្បីធ្វើបណ្តឹងសាទុក្ខថា "បណ្តឹងសាទុក្ខត្រូវធ្វើក្នុងរយៈពេលដូចតទៅ ៖ "*១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍*"។

នៅក្នុងផ្នែកវិនិច្ឆ័យសេចក្តីនៃសាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ឧ.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទី ៤ សរសេរថា "*សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨*"។

បទប្បញ្ញត្តិមាត្រា ៤២០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តថា "*កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតចាប់ពីថ្ងៃប្រកាសសាលដីកា*"។



Scanned with CamScanner

បទប្បញ្ញត្តិមាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តស្តីពីសាលក្រមចំពោះមុខ ត្រង់កថាខណ្ឌទី ១ ថា *"ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមជាសាលក្រមចំពោះមុខ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឱ្យដំណឹងដល់ជននេះទេ។............"*

២.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានវិនិច្ឆ័យសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បណ្តឹងសាទុក្ខលេខ ១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា មិនអាចទទួលយកបាន។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០៤ ក្រ.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] សុខា ទុកជាបានការដដែល។

-សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner